# Living the Lotus 4

## Buddhism in Everyday Life

2026
VOL. 247











## The Brazil Dharma Center Welcomes Rev. Takashi Maeda, Director of Rissho Kosei-kai International, on March 22


**Living the Lotus**
**Vol. 247 (April 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីស្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីស្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Na-ganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីស្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# ចំពោះមនុស្សដែលតូចចាម៉ិចៗប៉ុនផ្កាវីយោឡែត

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្សូក្កូសេកៃ



## កំណាព្យខ្លីរបស់ សូសេគី និងគាថាពេលព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត

នៅឆ្នាំ 1897 កវីនិពន្ធណាតស៊ឹម៉ិ សូសេគី បានផ្ញើកំណាព្យខ្លី "កើតមកតូចចាម៉ិចៗប៉ុនផ្កាវីយោឡែត" ទៅមិត្តជាទីស្រឡាញ់របស់គាត់គឺ ម៉ាសាវកា ស៊ីគី ។ កំណាព្យនេះសរសេរឡើងចំពេលដែលប្រទេសជប៉ុនមានបរិយាកាសរីករាយអស្ចារ្យដោយសារជ័យជម្នះរបស់ខ្លួននៅក្នុងសង្គ្រាមចិន-ជប៉ុន និងការដើរឆ្ពោះទៅកាន់ភាពជាប្រទេសទាន់សម័យនិយម។ ទោះជាយ៉ាងណាក៏ដោយ កំណាព្យនេះហាក់ដូចជាជោកជាំទៅដោយមនោសញ្ចេតនាដ៏សោកសៅរបស់កវីនិពន្ធសូសេគី ។

ការគោរពបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់ខ្លួន ហើយរស់នៅដោយមោទនភាពមានសារៈសំខាន់ណាស់សម្រាប់មនុស្ស។ ក៏ប៉ុន្តែទោះ ជាយ៉ាងណាក៏ដោយ ប្រសិនបើមានការយល់ច្រឡំ វាអាចនាំឱ្យកើតមានឡើងនូវភាពក្រអឺ តក្រទម មោទនភាពជ្រុលហួសហេតុ និងការបំភិតបំភ័យអ្នកដទៃ ហើយជួនកាលវាអាចរីករាលដាលទៅជាអារម្មណ៍ដ៏គ្រោះថ្នាក់ដោយការទទួលយកសង្គ្រាមទាំងហ្វូងទាំងហ្វាយផងដែរ។ ប្រឈមមុខនឹងការពិតបែបនេះ ខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ថា កំណាព្យរបស់កវីនិពន្ធសូសេគីនេះបង្កប់ទៅដោយក្តីប្រាថ្នាដែលចង់រស់ "ដូចជាផ្កាវីយោឡែតដែលរស់នៅជីវិតដ៏រឹងមាំរីកស្ងាត់ៗតាមដងផ្លូវមិនចាំបាច់ឱ្យនរណាគេស្គាល់ ហើយធ្វើខ្លួនឱ្យជាអត្ថិភាពដែលអាចលួងលោមនិងធ្វើឱ្យចិត្តអ្នកដែលបានឃើញខ្លួនបានកក់ក្តៅ"។

ថ្ងៃទី ៨ ខែមេសា ជាថ្ងៃបុណ្យប្រារព្ធថ្ងៃប្រសូតរបស់ព្រះសម្មាសម្ពុទ្ធ។ នៅពេលដែលយើងពិនិត្យពិច័យពីអត្ថន័យនៃគាថាពីកំណើតព្រះសម្មាសម្ពុទ្ធក្នុងគម្ពីរព្រះធម៌ ដែលចែងថានៅពេលប្រសូត្រមកភ្លាមព្រះពុទ្ធបានមានព្រះបន្ទូលថា "យើងគឺជាមនុស្សដ៏មានតម្លៃតែម្នាក់គត់ នៅក្រោមមេឃលើដីនេះ" ។ យើងអាចឃើញថាគាថានេះបង្រៀនយើងពីសារៈសំខាន់នៃភាពរាបសា ការបញ្ចាំងឆ្លុះពីខ្លួនឯងក៏ដូចជាការគោរពពិតប្រាកដចំពោះខ្លួនឯង និងអ្នកដទៃ ដែលស្របនឹងគំនិតរបស់កវីនិ ពន្ធសូសេគី ។

មនុស្សម្នាក់ៗសុទ្ធតែជាវត្ថុដ៏វិសេសវិសាល និងមានតម្លៃតែមួយគត់នៅលើលោកនេះ។ នៅពេលដែលយើងចាប់ភ្លឹកពីកត្តានេះ យើងនឹងយល់ថាភាពក្រអឺតក្រទមក្តីមហិច្ឆតាក្តី ការបង្កជម្លោះជាមួយអ្នកដទៃក្តីគឺជាទង្វើល្ងង់ខ្លៅប៉ុនណា។ ទន្ទឹមនឹងនោះដែរយើងយល់ថា ការគោរពខ្លួនឯង និងអ្នកដទៃព្រមទាំងការរស់នៅចុះសម្រុងនឹងអ្នកដទៃ គឺជាន័យនៃការដែលបានកើតមកជាមនុស្ស ហើយយើងក៏យល់ដែរថា ហេតុអ្វី

បានជាមាតាបិតាគ្រូអា
ចារ្យបង្រៀនប្រៀនប្រដៅយើងឱ្យចេះគិតថា "ការដឹងគុណ និងមេត្តាករុណា សំខាន់ជាងអ្វីៗទាំងអស់"នោះ។

ពោលគឺថាជាជាងរស់នៅដោយភាពក្រអឺត ក្រទមអឿដោយការពេញចិត្តមកលើខ្លួនឯង ទោះបីគ្រាន់តែជា "មនុស្សតូចច្រមុិចៗ" ដែលគ្មាននរណាស្គាល់ក៏ដោយ បើអត្ថិភាពរបស់យើងអាចនាំឱ្យចិត្តអ្នកដទៃបានកក់ក្តៅ,ការបង្កើតឱ្យមានភាពសុខដុមរមនាធ្វើឱ្យយើងមានក្តីសុខជាងនោះឆ្ងាយណាស់។

## អត្ថន័យនៃកំណើតនៃជីវិតរបស់យើង

កំណាព្យរបស់កវីនិពន្ធសូសេគី និយាយអំពីផ្កាតូចពណ៌ស្វាយឈ្មោះវីយោឡែត ប៉ុន្តែចំពោះអ្នកវិញតើអ្នកចង់ក្លាយជាផ្កាប្រភេទណា?

អ្នកប្រហែលជានឹងនឹកឃើញផ្កានានាដែលមានប្រជាប្រិយភាពនៅរដូវនេះដូចជាផ្កាចំប៉ាធំ (Ma g n o l i a ) , ផ្កាសាគូរ៉ា, ផ្កាស្ពៃរឿង (d a n d e l i o n ) ដែលរីកគួរឱ្យស្រឡាញ់ ហើយនិងផ្កាកញ្ចុំតូចៗ(D a p h n e )ដែលមានក្លិនក្រអូបផ្អែម ។ ដូចដែលអ្នកណាម្នាក់ធ្លាប់បាននិយាយថា "សម្រស់របស់ផ្កាមិនមានឋានានុក្រមទេ"ដែរ ផ្កានីមួយៗរីកទៅតាមសមត្ថភាពរបស់វាដោយមិនបែងចែកថាផ្កានេះគ្រាន់បើឬមួយថាផ្កានោះអន់ ឬថាផ្កានោះស្រស់ស្អាតហើយផ្កានោះមើលមិនបានឡើយនោះទេ។

ទស្សនវិទូនីស៊ីដា គីតារ៉ូ បាននិយាយយ៉ាងត្រឹមត្រូវថា៖

"ផ្កាស្រស់ស្អាតបំផុតនៅពេលដែលវាបង្ហាញពីធម្មជាតិពិតរបស់វា ដូច្នេះមនុស្សយើងក៏ឈានដល់ចំណុចកំពូលនៃភាពស្រស់ស្អាតនៅពេលដែលខ្លួនបង្ហាញពីធម្មជាតិពិតរបស់ខ្លួនដែរ"។

សម្រាប់យើងដែលសិក្សា និងរស់នៅតាមពាក្យបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធ ធម្មជាតិពិតរបស់មនុស្សគឺគ្មានអ្វីក្រៅពីធាតុព្រះពុទ្ធទេ ហើយនៅពេលដែលយើងម្នាក់ៗចាប់ ភ្លឹកថាយើងមានធាតុព្រះពុទ្ធនៅក្នុងខ្លួន ហើយខិតខំអភិវឌ្ឍធាតុព្រះពុទ្ធនោះ ជីវិតរបស់យើងនឹងរីកដូចជាផ្កា យើងនឹងអាចដើរលើមាគ៌ាត្រឹមត្រូវបំពេញកាតព្វកិច្ចសំដៅឆ្ពោះទៅរកគោលដៅរបស់យើងបាន។ នេះជាអត្ថន័យដ៏អស្ចារ្យនៃការកើតមកជាមនុស្ស។

ទោះជាយ៉ាងណាក៏ដោយ ពេលវេលាដែលមនុស្សម្នាក់ៗភ្ញាក់រលឹកពីអត្ថន័យនៃជីវិតវាខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ដូច្នេះជាពិសេសយុវវ័យមិនចាំបាច់ប្រញិបប្រញាប់ទេ។សេចក្តីបារម្ភអាចនាំឱ្យយើងក្លាយជាមនុស្សមិនចេះអត់ធ្មត់ ឬទុទិដ្ឋិនិយម។

កំណាព្យសាសនាមួយដែលខ្ញុំព្រះករុណាអាត្មាភាពចូលចិត្តគឺ "នៅក្នុងលោកនេះរស់នៅឱ្យតែរស់ដោយមានតែចិត្តល្អនិងបានបទទៅបានហើយ" (សាហ្សេង សេស្តេ)។

ជាមូលដ្ឋានគឺមានន័យថា សម្រាកចិត្តរបស់យើង កុំបីមានភាពសោកសៅ ខឹង ឬលោភលន់ចង់បានពេក ហើយរក្សាភាពស្មោះត្រង់ក្នុងអារម្មណ៍របស់យើងជានិច្ចមិនបាច់ចាំតែទៅជាមនុស្សលេចធ្លោទេ។

ជាពិសេសនៅក្នុងសម័យកាលដែលក្តីថប់បារម្ភ និងការមិនពេញចិត្តមានកាន់តែខ្លាំងឡើងបែបនេះ ខ្ញុំព្រះករុណាអាត្មាភាពសង្ឃឹមថា យើងម្នាក់ៗនឹងមិនភ្លេចឥរិយាបទ គិតអ្នកដទៃមុន និងធ្វើឱ្យផ្កាដែលមានតែមួយគត់របស់យើងរីកបាន។

កាសែតកូសេ ខែ៤ឆ្នាំ២០២៦






# A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp